៣–លោក **លឹម សេងលី** នៅសហរដ្ឋអាមេរិក ជួយឧបត្ថម្ភប្រាក់ ៨៦០ ដុល្លារអាមេរិក

៤–លោក **ឌុច ឡើន** នៅសហរដ្ឋអាមេរិក ជួយឧបត្ថម្ភប្រាក់ ៨១០ ដុល្លារអាមេរិក

៥–លោក **សូ សុផល** នៅសហរដ្ឋអាមេរិក ជួយឧបត្ថម្ភប្រាក់ ៦៦០ ដុល្លារអាមេរិក

**ប្រការ ២ :** នាយកដ្ឋានប្រឡងប្រណាំង និងគ្រឿងឥស្សរិយយស នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានសរុប ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយទទួលបានលទ្ធផលល្អ ។

**សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា និង ត្រា**

**សុខ អាន វេងសិរីវុឌ្ឍ**

* * *

## ៣ - សារាចរ

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

**សារាចរលេខ ០២ សរ**

**ស្តីពីការរៀបចំធ្វើគំរោងប្លង់គោល នៅតាម**

**ខេត្ត–ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា**

* * *

ចាប់តាំងពីរាជរដ្ឋាភិបាល ត្រូវបានបង្កើតឡើងរហូតមកដល់បច្ចុប្បន្ន វិស័យសេដ្ឋកិច្ចសង្គមមានការរីកចំរើនលូតលាស់គួរអោយមានមោទនភាព ។ ដោយឡែកការស្តារ និងការកសាងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និង សំណង់ក៏កំពុងមានសន្ទុះឈានទៅមុខយ៉ាងខ្លាំងក្លា ។ ប៉ុន្តែរាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី ការស្ថាបនារោងចក្រ សណ្ឋាគារ ភោជនីយដ្ឋាន ការស្ថាបនា ទីផ្សារ ការធ្វើសួនច្បារ ឧទ្យានសាធារណៈ តំបន់អភិវឌ្ឍន៍មជ្ឈមណ្ឌលទេសចរណ៍ តំបន់លំហែរកំសាន្ត ជាពិសេសលំនៅដ្ឋាន ហាងលក់ដូរទំនិញរបស់ប្រជារាស្ត្រ បានបង្កឡើងនូវភាពមិនសមស្របតាមបច្ចេកទេសនៃការរៀបចំទឹកដី នគរូបនីយកម្ម

និងសំណង់ ហើយសំណង់ភាគច្រើនបាន និងកំពុងសាង សង់ទៀតដោយអនាធិបតេយ្យធ្វើអោយខូចសោភ័ណភាពដល់ប្រជុំជន ទីរួមស្រុក ទីរួមខេត្ត និងទីក្រុង ។

ដើម្បីដោះស្រាយបញ្ហានេះ ដែលមានលក្ខណៈចាំបាច់ និងបន្ទាន់ចំពោះអនាគតរបស់ជាតិមាតុភូមិ អង្គរដ៏បវរនៃយើង រាជរដ្ឋាភិបាល សូមធ្វើការណែនាំចំពោះក្រសួង ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង អោយអនុវត្តនូវវិធានការសំខាន់ៗ ដូចខាងក្រោម ៖

អនុលោមតាមច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ នៅជំពូកទី ២ មាត្រា ៥ ដែលបានចែងថា «គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬ អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង នីមួយៗ ត្រូវគូសប្លង់គោល ដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍ នៃធានីភ្នំពេញ ខេត្ត-ក្រុងរបស់ខ្លួន ។ ប្លង់គោលនេះ ត្រូវមានការយល់ព្រមពី គណៈកម្មធិការជាតិ រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និង កំណត់ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភ័ណ្ឌ ការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ច ចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិ រៀបចំទឹកដីនគរូប-នីយកម្ម និង សំណង់ មានការរៀបចំប្លង់គោល សំរាប់តំបន់ ពិសេសនោះ ដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត »។

១-ដើម្បីប្រតិបត្តិច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃ ទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៤ អោយមានប្រសិទ្ធភាព រាជរដ្ឋាភិបាល សូមប្រគល់ភារកិច្ច ជូនក្រសួងមហាផ្ទៃ ណែនាំដល់សាលាក្រុងភ្នំពេញ និងសាលាខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រ កម្ពុជាត្រូវសហការជំរុញផ្នែកជំនាញ នៃគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយ៍កម្ម និងសំណង់ រាជធានីភ្នំពេញ និងអនុគណៈកម្មាធិការរៀបចំ ទឹកដីនគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង អោយដំណើរការជាបន្ទាន់ នូវការគូសប្លង់គោល ដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍នៃរាជធានី ខេត្ត-ក្រុងរបស់ខ្លួន ដែលក្នុងនោះ ត្រូវកំណត់អំពីហេដ្ឋារចនាសម្ព័ន្ធ បណ្តាញផ្លូវគមនាគមន៍ ទីតាំងទីផ្សារ តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់សណ្ឋាគារ មណ្ឌលទេសចរណ៍ តំបន់កំពង់ផែ ចំណតរថយន្ត ចំណតរថភ្លើង ចំណតអាកាសយានដ្ឋាន តំបន់សាលារៀនចំណេះ ទូទៅសាលារៀនបច្ចេកទេសទីវត្តអារ៉ាម តំបន់រដ្ឋបាលស៊ីវិលតំបន់នគរបាល តំបន់យោធា តំបន់ការពារបរិស្ថាន តំបន់សួនច្បារ ឧទ្យានសាធារណៈ កន្លែងចាក់សំរាមអាងស្តុកទឹកសំអុយ បណ្តាញលូបង្ហូរទឹក ការរៀបចំខ្សែបណ្តាញអគ្គិសនី ដីត្រៀមបំរុងអភិវឌ្ឍន៍

ព្រៃត្រៀមបម្រុង ជំរកសត្វព្រៃ បឹងបួរសាធារណៈ ទន្លេ ព្រែក សមុទ្រ កោះ ដីលំនៅដ្ឋានដីធ្វើស្រែចំការច្បារ ដំណាំផ្សេងៗ ។ល។

២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ រួមជាមួយក្រសួងគ្រប់គ្រងបរិស្ថានត្រូវធ្វើការណែនាំជា បន្ទាន់ដល់មន្ទីរក្រោមឱវាទរបស់ខ្លួននៅគ្រប់ខេត្ត-ក្រុង អោយធ្វើការសិក្សា អំពីមុខជំនាញក្នុងការកំណត់ តំបន់ដីធ្លីសំរាប់ដំណាំកសិកម្ម ដំណាំកសិ-ឧស្សាហកម្ម និងដំណាំយុទ្ធសាស្ត្រផ្សេងៗ កំណត់តំបន់ដី សម្បទាន កំណត់តំបន់ព្រៃសម្បទាន តំបន់រោងចក្រឧស្សាហកម្ម មណ្ឌលទេសចរណ៍ ព្រៃឧទ្យានជាតិ ជំរកសត្វព្រៃ កសាងហេដ្ឋារចនាសម្ព័ន្ធ ។ល។ ដើម្បីរួមបញ្ចូលនៅក្នុងគំរោងប្លង់គោលតាមខេត្ត-ក្រុង នីមួយៗ សំដៅឈានទៅរៀបចំធ្វើប្លង់គោលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាមូលដ្ឋានជូន គណៈរដ្ឋមន្ត្រី ក្នុងការសំរេចកំណត់ដីធ្លី និងតំបន់ផ្សេងៗ សំរាប់ប្រគល់អោយក្រុមហ៊ុននានាធ្វើវិនិយោគ បំរើអោយការអភិវឌ្ឍន៍ប្រទេសជាតិ ធានាបាននិរន្តរ៍ភាពតទៅអនាគត និងធានាបានកិច្ចការពារបរិស្ថានទៀតផង ។

៣-គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវធ្វើការណែនាំអំពីការងារ បច្ចេកទេសជំនាញលើការងាររៀបចំទឹកដី ការងារនគរូបនីយកម្ម និងការងារសំណង់ ទៅដល់គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ និងអនុគណៈ-កម្មាធិការរៀបចំ ទឹកដីនគរូបនីយកម្ម និង សំណង់ខេត្ត-ក្រុង អោយធ្វើជាសេនាធិការជូនអភិបាលខេត្ត-ក្រុង ក្នុងការរៀបចំធ្វើគំរោងប្លង់គោល ដើម្បីធ្វើការរៀបចំ និង អភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌវង្វង់ដែនដីដែល ខេត្ត-ក្រុងនីមួយៗ គ្រប់គ្រង ។

ទទួលបានសារាចរនេះ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រង បរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់សាលាខេត្ត-ក្រុង ត្រូវចាត់ចែងផ្សព្វផ្សាយ និងទទួលអនុវត្ត អោយបានលទ្ធផលល្អប្រសើរ រួចសូមផ្ញើប្លង់គោលនេះ ចំនួន ៤ ច្បាប់មកសុំការឯកភាព ពីក្រសួងមហាផ្ទៃជាមុន រួចទើបបញ្ជូនទៅគណៈកម្មាធិការជាតិរៀបចំទឹកដី

នគរូបនីយកម្ម និងសំណង់ពិនិត្យ និង សុំការសំរេចពីរាជរដ្ឋាភិបាលអោយបានមុនដំណាច់ខែ កក្កដា ឆ្នាំ ១៩៩៦ ជាកំហិត ។

**នាយករដ្ឋមន្ត្រីទី ១**

**ព្រះហស្ថលេខា និងត្រា**

**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**

**ហត្ថលេខា និង ត្រា**

**ហ៊ុន សែន**

* * *

# II - ការងារបណ្តាក្រសួង

## ១ - នីតិការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០០៣ សហវ.នរ**

**ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការឯកជនភាវូបនីយកម្ម**

**សហគ្រាសសាធារណៈ និងលេខាធិការដ្ឋាន**

**ដើម្បីអនុវត្តអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤